**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**រាជធានីភ្នំពេញ, ថ្ងៃទី០៤..ខែ.៩.៧...ឆ្នាំ ២០១៧**

លេខ:...៩២០..វសល.៧

អង្គភាពលទ្ធកម្មក្រសួង
អង្គភាពបេកជ្រាយលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃការងារជួសជុលបន្ទប់បច្ចេកទេសសាលាតូតន្ត្រី សាលាសូនរូប និងចាក់បេតុងផ្លូវចូលសាលាមធ្យមវចិត្រសិល្បៈ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល) និងក្រុមហ៊ុនបរទេសទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវ ក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យបានជ្រាបថា ៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ លើការងារជួសជុលបន្ទប់បច្ចេកទេសសាលាតូតន្ត្រី សាលាសូនរូប និងចាក់បេតុងផ្លូវចូលសាលាមធ្យមវិចិត្រសិល្បៈ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ស្ថិតនៅអគារលេខ២២៧ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី០៣ ខែ៩៧ ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ ។ ប្រាក់ទិញឯកសារដេញថ្លៃ មិនអាចបង្វិលជូនវិញបានឡើយ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង០៩:០០ ។ រាល់សំណើដេញថ្លៃដែលដាក់ក្រោយកាលបរិច្ឆេទកំណត់ នឹងត្រូវបដិសេធ ។

សំណើដេញថ្លៃ នឹងត្រូវបើកជាសាធារណៈ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) នៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៩:១០ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៧ ជាកំហិត និងដោយមានវត្តមានចូលរួមពីក្រុមហ៊ុនផ្គត់ផ្គង់ ឬតំណាងស្របច្បាប់ ។

សំណើដេញថ្លៃទាំងអស់ត្រូវភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃចំនួន០២ភាគរយ ស្មើនឹង១២ ៩៨៥ ៩០០,០០រៀល (ដប់ពីរលាន ប្រាំបួនរយប៉ែតសិបប្រាំពាន់ ប្រាំបួនរយរៀលគត់) ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូ ដូចមានរៀបរាប់នៅក្នុងសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរពត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

ភឿង-សកុណា

ចម្លងជូន:
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"
-អង្គភាពប្រឆាំងអំពើពុករលួយ

ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ